**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការយោធា**

-សំណុំរឿងព្រហ្មទណ្ឌលេខ ០០២

ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១

-សាលក្រមព្រហ្មទណ្ឌលេខ ០១៨

ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការយោធា

អនុវត្តតាមមាត្រា៨១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅតុលាការយោធា កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានតុលាការយោធា ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងយោធា ជាតំណាងអយ្យការធានាបណ្តឹងអាជ្ញាក្នុងពេលសវនាការ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជីក្នុងពេលសវនាការ

លោក [redacted] ជាជំនួយការក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

- ឈ្មោះ [redacted] **ម៉ុនធឿន** ភេទប្រុស អាយុ ៤១ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ គក់ដេដី និងគក់ដេរថយន្ត, កម្រិតវប្បធម៌ ថ្នាក់បរិញ្ញាបត្រ ផ្នែកគ្រប់គ្រង កើតនៅ ភូមិ [redacted]

[redacted], ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ប្រពន្ធឈ្មោះ [redacted] (រស់) មានកូនចំនួន ០២ នាក់, ជានីតិជន, ទីលំនៅមុនពេលឃាត់ខ្លួន ភូមិអូរគន្ធត្បូង សង្កាត់អូរគន្ធ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ, ទោសពីមុនគ្មាន, ឃាត់ខ្លួនៈ ០៦ មីនា ២០២១, ឃុំខ្លួនៈ ១២ មីនា ២០២១ ដោយមានលោក [redacted] សុភាវុធ ជាមេធាវីការពារក្តី។

ជាប់ចោទពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសម្លៀកបំពាក់ជាអាទិ៍ សម្រាប់អាជ្ញាធរសាធារណៈ, ប្រើប្រាស់មិនប្រក្រតីឋានៈណាមួយ, ឆបោក, កាន់កាប់លាក់ទុកអាវុធគ្រាប់រំសេវដោយខុសច្បាប់, ទិញលាក់ទុក ប្រើប្រាស់បរិក្ខាររបស់កងទ័ព និងក្លែងបន្លំឯកសារសាធារណៈ (ប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិ និងអត្តសញ្ញាណប័ណ្ណនាយទាហាន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងខេត្តកំពង់ធំ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, ៣៧៨, ៦១២, ៦២០, ៦២៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ និងមាត្រា៤ នៃក្រឹត្យច្បាប់លេខ០៤ ស្តីពីបទល្មើសមានលក្ខណៈយោធានិងទណ្ឌកម្ម។

ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះមានឈ្មោះដូចខាងក្រោម ៖

១/. ឈ្មោះ [redacted] **ធី** ភេទប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ នាយរដ្ឋបាលសង្កាត់ព្រៃឈើអង្គរជ័យ, កម្រិតវប្បធម៌ ថ្នាក់ទី១២ មានទីលំនៅបច្ចុប្បន្ន [redacted]។

២/. ឈ្មោះ [redacted] **សំបូរ** ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ និស្សិត, កម្រិតវប្បធម៌ បរិញ្ញាបត្រឆ្នាំទី២ មានទីលំនៅបច្ចុប្បន្ន [redacted]។

៣/. ឈ្មោះ [redacted] **ស៊ីផូ** ភេទស្រី អាយុ ៥០ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ មេផ្ទះ, កម្រិតវប្បធម៌ ថ្នាក់ទី៧ (ចាស់) មានទីលំនៅបច្ចុប្បន្ន [redacted]។

៤/. ឈ្មោះ [redacted] **ខិននិមល** ភេទប្រុស អាយុ ៣៦ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ ពេទ្យយោធា, កម្រិតវប្បធម៌ ថ្នាក់ទី១២ មានទីលំនៅបច្ចុប្បន្ន [redacted]។

## អង្គហេតុនៃការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីអំឡុងខែឧសភា ឆ្នាំ២០១៧ ដល់ អំឡុងខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] **ម៉ុនធឿន** ភេទប្រុស អាយុ ៤១ឆ្នាំ ជាជនស៊ីវិល (មានសាវតារជាតិដូចខាងលើ) បានធ្វើសកម្មភាពកាត់តក្លែងប្រកាសនីយបត្រគ្រឿងឥស្សរិយយសជាគូបការ, កាត់តក្លែងវិញ្ញាបនបត្របញ្ជាក់ការសិក្សា និងកាត់តក្លែងប័ណ្ណសរសើរ ដែលចេញដោយក្រសួងការពារជាតិ ព្រមទាំងបានប្រើប្រាស់ និងស្លៀកពាក់ឯកសណ្ឋានយោធា ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ ដោយបានកាត់តផ្គិតរូបថត ជាមួយថ្នាក់ដឹកនាំក្រសួងការពារជាតិមាន រូបថតកាត់តជាមួយ ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង និងជាមេ

បញ្ជាការកងទ័ពជើងគោក, នាយឧត្តមសេនីយ៍ សំ វណ្ណថន អគ្គលេខាធិការក្រសួងការពារជាតិ, សម្ដេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ, ដោយបានដាក់រូបថតទាំងនេះបង្ហាញនៅត្រង់កន្លែងទទួលភ្ញៀវក្នុងផ្ទះរបស់ខ្លួន នាំឱ្យអ្នកដែលបានចូលលេងក្នុងផ្ទះនោះមើលឃើញនិងយល់ឃើញថាខ្លួនជានាយទាហានជាន់ខ្ពស់។ ឈ្មោះ [redacted] ប៊ុនធឿន បានប្រើឋានៈឧត្តមសេនីយ៍ទោដោយពេលខ្លះ បានស្លៀកពាក់ឯកសណ្ឋានយោធា ហើយពេលខ្លះបានយកឯកសណ្ឋានយោធាដាក់ព្យួរនៅក្នុងរថយន្ត នៅពេលធ្វើដំណើរ ដោយប្រើប្រាស់រថយន្តពាក់ផ្លាកលេខខេមរភូមិន្ទ និងបានអួតអាងពីតួនាទីមុខតំណែងប្រាប់អ្នកដទៃ។ បន្ទាប់មកឈ្មោះ [redacted] ប៊ុនធឿន បានទទួលប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ ពីឈ្មោះ [redacted] ធី ដោយធានាអះអាង ជួយរត់ការបញ្ចូលក្របខ័ណ្ឌឱ្យឈ្មោះ [redacted] សំបូរ ជាកូនប្រុសរបស់ឈ្មោះ [redacted] ធី ចូលធ្វើជាយោធិននៃកងយោធពលខេមរភូមិន្ទ។ ក្រោយមកឈ្មោះ [redacted] ប៊ុនធឿន បានទទួលប្រាក់ចំនួន ១៤.០០០ (មួយម៉ឺនបួនពាន់) ដុល្លារ ពីឈ្មោះ [redacted] ស៊ីផូ ដោយធានាអះអាងជួយឱ្យកូនប្រុសរបស់ឈ្មោះ [redacted] ស៊ីផូ ប្រឡងជាប់ចូលធ្វើទាហានជើងទឹក។ ក្រោយមកទៀតឈ្មោះ [redacted] ប៊ុនធឿន បានទទួលប្រាក់ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារ ពីឈ្មោះ [redacted] ជិននិមល ដោយធានាអះអាងជួយរត់ការផ្ទេរអង្គភាពឱ្យឈ្មោះ [redacted] ជិននិមល ពីអង្គភាពទាហានជើងទឹកទៅធ្វើការងារនៅអង្គភាព យោធភូមិភាគពិសេស។ លើសពីនេះឈ្មោះ [redacted] ប៊ុនធឿន បានក្លែងបន្លំអត្តសញ្ញាណប័ណ្ណនាយទាហានចំនួន ០១ (មួយ) សន្លឹក និងក្លែងបន្លំប្រកាសស្ដីពីការដំឡើងឋានន្តរស័ក្តិអនុសេនីយ៍ឯក [redacted] សំបូរ ចំនួន ០១ (មួយ) សន្លឹក យកទៅប្រគល់ឱ្យឈ្មោះ [redacted] ធី និងឈ្មោះ [redacted] សំបូរ ដើម្បីបិទបាំងទង្វើឆបោក និងការកិបកេងទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអំពើខាងលើនេះនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរកងយោធពលខេមរភូមិន្ទ។ ក្រៅពីនេះឈ្មោះ [redacted] ប៊ុនធឿន បានកាន់កាប់ និងរក្សាទុកអាវុធខ្លីចំនួន ០១ (មួយ) ដើម នៅក្នុងផ្ទះ ដែលការកាន់កាប់អាវុធនេះ ពុំមានលិខិតអនុញ្ញាតឱ្យប្រើប្រាស់នោះទេ។

## អង្គច្បាប់ដែលដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យចំពោះអង្គហេតុ

តាមបញ្ញត្តិមាត្រា៣៧៧, ៣៧៨, ៦១២, ៦២០, ៦២៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២០ នៃច្បាប់ស្ដីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ និងមាត្រា៤ នៃក្រឹត្យច្បាប់លេខ០៤ ស្ដីពីបទល្មើសមានលក្ខណៈយោធានិងទណ្ឌកម្ម។

បានឃើញរបាយការណ៍សរុបលេខ០០២/របក ២០២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់ស្នងការដ្ឋានស្រាវជ្រាវព័ត៌មានសន្តិសុខ កងរាជអាវុធហត្ថលើផ្ទៃប្រទេស។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ០០២ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ០១១/២០២១ ដ.ក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមតុលាការយោធា។

បានឃើញសំណុំរឿងស៊ើបសួរលេខ០០៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃតុលាការយោធា។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ១៩៥/០២២ ដ.ក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃតុលាការយោធា។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ០១១/២០២២ ដ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមតុលាការយោធា។

បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២០២/០២២ ដ.ក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២២ របស់ចៅក្រមស៊ើបសួរនៃតុលាការយោធា។

បានឃើញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ០០៤/០២២ ដ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០២២ របស់ប្រធានតុលាការយោធា។

បានឃើញដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ០០៩/០២២ ដ.ក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០២២ របស់ក្រុមប្រឹក្សាជំនុំជម្រះតុលាការយោធា។

បានឃើញពាក្យសុំពន្យារពេលសវនាការលេខ០០១២/២០២២ ក.ម.ជ.យ.អ ចុះថ្ងៃទី១១ ខែ ឧសភា ឆ្នាំ២០២២ របស់មេធាវីការពារក្តីឱ្យជនជាប់ចោទ។

បានឃើញដីកាសម្រេចលើកពេលជំនុំជម្រះលេខ០១៣/០២២ ដ.ក ចុះថ្ងៃទី១២ខែឧសភា ឆ្នាំ ២០២២ របស់ក្រុមប្រឹក្សាជំនុំជម្រះតុលាការយោធា។

## អង្គហេតុក្នុងពេលសវនាការ

លោក[redacted]តំណាងអយ្យការអមតុលាការយោធា ឡើងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ទោស តាមដីកាសន្និដ្ឋានស្ថាពរលេខ០១១/២០២២ ដ.ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់តំណាងអយ្យការអមតុលាការយោធា ដោយចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសម្លៀកបំពាក់ជាអាទិ៍ សម្រាប់អាជ្ញាធរសាធារណៈ, ប្រើប្រាស់មិនប្រក្រតីឋានៈណាមួយ, ឆបោក, កាន់កាប់លាក់ទុកអាវុធគ្រាប់រំសេវដោយខុសច្បាប់, ទិញលាក់ទុក ប្រើប្រាស់បរិក្ខាររបស់កងទ័ព និងក្លែងបន្លំឯកសារសាធារណៈ (ប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិ និងអត្តសញ្ញាណប័ណ្ណនាយទាហាន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងខេត្តកំពង់ធំ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧, ៣៧៨, ៦១២, ៦២០, ៦២៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ និងមាត្រា៤ នៃក្រឹត្យច្បាប់លេខ០០៤ ស្តីពីបទល្មើសមានលក្ខណៈយោធានិងទណ្ឌកម្ម។

ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន បានឆ្លើយថា ខ្ញុំស្តាប់បាននូវខ្លឹមសារនៃការចោទប្រកាន់ទោស របស់តំណាងអយ្យការអមតុលាការយោធា ប៉ុន្តែខ្ញុំមានយោបល់ថា តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានចោទមកលើរូបខ្ញុំ គឺមិនប្រក្រតីឡើយ ដែលធ្វើឱ្យខ្ញុំមិនអាចទទួលយកបាននោះទេ។

ជនជាប់ចោទឈ្មោះ [redacted]ប៊ុនធឿន បានឆ្លើយថា កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៧ ខ្ញុំធ្លាប់បានចូលបម្រើទ័ព ជាជំនួយការលេខាធិការដ្ឋាន នៅនាយកដ្ឋានវិស្វកម្មក្រសួងការពារជាតិ មានឋានន្តរស័ក្តិអនុសេនីយ៍ត្រី ប៉ុន្តែខ្ញុំបានលាឈប់ពីកងទ័ពវិញ កាលពីឆ្នាំ២០១៧ មូលហេតុដោយសារខ្ញុំចង់ដូរអង្គភាពពីកងវិស្វកម្ម ទៅអង្គភាពសម្ភារៈបច្ចេកទេសមិនបាន ហើយកាលពេលខ្ញុំធ្វើការនៅអង្គភាព

នោះ ខ្ញុំមិនដែលបានទទួលប្រាក់ខែទៀងទាត់នោះទេ។ ចំពោះឯកសណ្ឋានយោធាទាំងនេះ គឺនៅសល់តាំងពីខ្ញុំនៅធ្វើជាកងទ័ពម្លេះ ដែលកាលនោះខ្ញុំមានឋានន្តរស័ក្តិវរសេនីយ៍ទោ ហើយខ្ញុំបានស្លៀកពាក់ឯកសណ្ឋាន ក្នុងឋានន្តរស័ក្តិជាឧត្តមសេនីយ៍ទោ គឺពុំមាននរណាបំពាក់ឱ្យខ្ញុំឡើយ ខ្ញុំគ្រាន់តែស្លៀកពាក់ដើម្បីថតរូបប៉ុណ្ណោះ ពេលថតរួចខ្ញុំដោះចេញវិញ។ រូបថតកាត់តនេះ ព្រោះខ្ញុំស្រឡាញ់រូបថតក្នុងឯកសណ្ឋានផ្កាយពីរជាមួយថ្នាក់ដឹកនាំ ចំពោះឯកសារ និងអាវុធដែលដាក់បង្ហាញនៅទីនេះ សមត្ថកិច្ចចាប់យកពីក្នុងផ្ទះរបស់ខ្ញុំ ហើយរូបថតទាំងអស់នេះ គឺជាងថតជាអ្នកកាត់តធ្វើឱ្យខ្ញុំទាំងអស់។ ចំពោះអាវុធនេះ គឺឈ្មោះ [redacted] វណ្ណៈ ប្រគល់មកឱ្យខ្ញុំកាលពីខ្ញុំនៅបម្រើកងទ័ព សម្រាប់ប្រើប្រាស់ពេលចុះបេសកកម្ម ប៉ុន្តែបេសកកម្ម និងប័ណ្ណអាវុធផុតកំណត់ ខ្ញុំបានយកអាវុធទៅប្រគល់ឱ្យឈ្មោះ [redacted] វណ្ណៈវិញដែរ ប៉ុន្តែទៅមិនជួប ខ្ញុំក៏ទៅអង្គភាពដើម្បីសុំបន្តសុពលភាព សម្រាប់ទុកចុះបេសកកម្មពេលក្រោយ ប៉ុន្តែអង្គភាពមិនបានចេញឱ្យទេ ហើយខ្ញុំក៏ទុកអាវុធនេះនៅផ្ទះរហូតតែម្តងទៅ។ ខ្ញុំគ្មានបំណងលាក់ទុកអាវុធនោះទេ គ្រាន់តែរក្សាទុកបណ្តោះអាសន្នសិន គ្មានគោលបំណងអ្វីផ្សេងឡើយ ព្រោះខ្ញុំបានយកទៅប្រគល់ឱ្យគេវិញដែរ ប៉ុន្តែដោយសារមិនជួប ហើយភ្លាមនោះមិនដឹងជាប្រគល់ឱ្យនរណា ក៏យកមកទុកនៅផ្ទះសិនទៅ។ រីឯប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិ អនុសេនីយ៍ឯក [redacted] សំបូ គឺខ្ញុំទទួលបានពី ឯកឧត្តម [redacted] ឈាង ប៉ុន្តែគាត់ស្លាប់បាត់ហើយ។

ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន បានឆ្លើយបន្តទៀតថា ខ្ញុំស្គាល់ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] សំបូ តាមរយៈលោក [redacted] រ៉ុងណាយ ជាអ្នកណាត់ឱ្យជួបគ្នានៅហាងចំការនននោងភ្នំពេញ។ ក្រោយមក ខ្ញុំបានទាក់ទងទៅ ឯកឧត្តម [redacted] ឈាង ឱ្យជួយឈ្មោះ [redacted] សំបូ បានចូលធ្វើទាហាន ហើយគាត់ប្រាប់វិញថាគាត់អាចជួយបានក្នុងតម្លៃ ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ បន្ទាប់មកខ្ញុំក៏ឱ្យលោក [redacted] រ៉ុងណាយ ណាត់ជួបគ្នាម្តងទៀតនៅចំការននោងដដែល។ ខ្ញុំបានទទួលប្រាក់ពីឈ្មោះ [redacted] ធី ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ រួចយកប្រាក់នេះទៅប្រគល់ឱ្យឈ្មោះ [redacted] ឈាង ចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លារ និងប្រគល់ឱ្យឈ្មោះ [redacted] រ៉ុងណាយ ចំនួន ១.០០០ (មួយពាន់) ដុល្លារ ។

តំណាងអយ្យការសួរដេញដោល ជនជាប់ចោទបានឆ្លើយថា ខ្ញុំរៀនចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ហើយពេលដែលខ្ញុំចូលធ្វើទ័ពដំបូង ខ្ញុំមិនដឹងថាខ្ញុំស៊ីឈ្មោះគេនោះទេ ប៉ុន្តែកាលនោះមេរបស់ខ្ញុំឈ្មោះ [redacted] វណ្ណ បានយកប្រាក់ពីខ្ញុំចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារ ។ ខ្ញុំជាប់ឃុំរយៈពេល ១៥ (ដប់ប្រាំ) ខែ មកហើយ, សមត្ថកិច្ចឃាត់ខ្លួនខ្ញុំពេលដែលខ្ញុំកំពុងលក់ដី នៅខេត្តបន្ទាយមានជ័យ ដោយអានដីកាពីបទប្រើប្រាស់ឋានៈក្លែង ឆបោក និងក្លែងបន្លំឯកសារសាធារណៈ។ ចំពោះឯកសារ និងរូបថតទាំងនេះ ខ្ញុំមិនបានធ្វើខ្លួនឯងនោះទេ ហើយខ្ញុំក៏មិនទទួលបានផលប្រយោជន៍អ្វីនោះដែរ គឺខ្ញុំស្រឡាញ់កងទ័ព ពាក់ឯកសណ្ឋានថតរូប រួចដោះចេញវិញ មិនបានស្លៀកពាក់ឯកសណ្ឋានផ្កាយពីរចេញទៅណានោះឡើយ។

លោកមេធាវីសួរដេញដោល ជនជាប់ចោទបានឆ្លើយថា ខ្ញុំបានទទួលប្រាក់ពីឈ្មោះ [redacted] ស៊ីផូ ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារ, គាត់លក់ដីនៅខេត្តកំពង់ស្ពឺ ហើយបានផ្ញើប្រាក់មកឱ្យខ្ញុំ ចំនួន ១១.៧០០ (មួយម៉ឺនមួយពាន់ប្រាំពីររយ) ដុល្លារ តាម ABA (អេប៊ីអេ)។ ខ្ញុំបញ្ជាក់ថា ខ្ញុំបានទទួលប្រាក់ពីឈ្មោះ [redacted] ស៊ីផូ ចំនួន ១១.៧០០ (មួយម៉ឺនមួយពាន់ប្រាំពីររយ) ដុល្លារ តាម ABA (អេប៊ីអេ) ហើយខ្ញុំបាន

សងទៅគាត់វិញចំនួន ៥.៧០០ (ប្រាំពាន់ប្រាំពីរយ) ដុល្លារ រួចហើយ ប៉ុន្តែពុំមានធ្វើលិខិតស្នាមនោះទេ។ ដំបូងឡើយ ខ្ញុំស្គាល់គ្នាជាមួយឈ្មោះ [redacted] បុប្ផា ដែលជាកូនស្រីគាត់ ហើយខ្ញុំបានខ្ចីប្រាក់ពីកូនស្រីគាត់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារ រឿងការងាររកស៊ី ក្រោយមកក៏បានស្គាល់គាត់។ គាត់និយាយប្រាប់ខ្ញុំថា គាត់ចង់ឱ្យកូនប្រុសរបស់គាត់ឈ្មោះ [redacted] វឌ្ឍា ចូលធ្វើជាទាហាន ពេលនោះខ្ញុំក៏និយាយថា នៅខាងជើងទឹកមានគេជ្រើសរើសទ័ពថ្មី ហើយគាត់ និងកូនស្រីបានពឹងពាក់ខ្ញុំឱ្យជួយកូនប្រុសចូលធ្វើទាហានផង។ រួចក៏ព្រមព្រៀងគ្នារឿងប្រាក់ជំពាក់ ៦.០០០ (ប្រាំមួយពាន់) ដុល្លារ បង្វិលទៅជាថ្លៃប្រាក់ជួយរត់ការចូលទ័ពវិញ រីឯប្រាក់ចំនួន ១១.៧០០ (មួយម៉ឺនមួយពាន់ប្រាំពីរយ) ដុល្លារ គឺជាប្រាក់ដែលខ្ញុំខ្ចីគាត់ មិនមែនជាប្រាក់សម្រាប់រត់ការ ឱ្យកូនគាត់ចូលធ្វើទាហាននោះទេ ហើយចំពោះរឿងប្រាក់ចំនួន ១៤.០០០ (មួយម៉ឺនបួនពាន់) ដុល្លារ ខ្ញុំមិនបានទទួលពីគាត់ និងមិនដឹងរឿងនោះទេ។

លោកមេធាវី បានលើកឡើងថា ទោះបីរូបខ្ញុំជាមេធាវីការពារក្ដីឱ្យជនជាប់ចោទក៏ពិតមែន ប៉ុន្តែខ្ញុំមានឆន្ទៈសុចរិត ហើយចង់ឱ្យកូនក្ដីរបស់ខ្ញុំសម្ដែងការស្មោះត្រង់ និងឆ្លើយឱ្យមានហេតុផល។ រឿងរូបថតទាំងនេះ មិនដែលជាងថតគេនឹកឃើញធ្វើឱ្យយើងនោះទេ លុះត្រាតែមានសំណើពីយើងដែរ ទើបខាងជាងថតគេធ្វើឱ្យបាន។

ជនជាប់ចោទ បានឆ្លើយថា ចំពោះរូបថតទាំងអស់នេះ ខ្ញុំយកពីកន្លែងផ្ដិតរូប ប៉ុន្តែខ្ញុំមិនបានធ្វើខ្លួនឯងនោះទេ ជាងថតជាអ្នកផ្ដល់យោបល់ឱ្យខ្ញុំថា បើកាត់តរូបជាមួយសម្ដេចពិជ័យទៀតកាន់តែសម ហើយខ្ញុំក៏ឱ្យគេធ្វើតែម្ដងទៅ ដោយសារតែខ្ញុំស្រឡាញ់ថ្នាក់ដឹកនាំ និងស្រឡាញ់សម្ដេចពិជ័យសេនា។ បន្ទាប់មកខ្ញុំក៏យកមកដាក់តាំងនៅក្នុងផ្ទះទុកមើល សម្រាប់មិត្តភក្ដិ បងប្អូន និងក្រុមគ្រួសារ ដោយគ្មានបំណងអួតអាង ឬដើម្បីឆបោកនរណានោះទេ។ ចំពោះអាវុធវិញ ខ្ញុំគ្រាន់តែរក្សាទុកសិន រង់ចាំ ប្រគល់ឱ្យគេវិញពេលក្រោយ ហើយខ្ញុំមិនដែលយកអាវុធនេះទៅសម្លុត ឬបង្ហាញគេ និងមិនដែលយកទៅគំរាមកំហែង ឬឆក់ប្លន់នរណាម្នាក់ឡើយ។ ចំពោះសម្លៀកបំពាក់ឯកសណ្ឋានវិញ ក៏ខ្ញុំមិនដែលស្លៀកពាក់ទៅណាដែរ ហើយក៏មិនដែលយកឯកសណ្ឋានទៅប្រព្រឹត្តបទល្មើសអ្វីដែរ។ មានតែក្រុមគ្រួសារ និងលោក [redacted] រ៉ុងណយ ប៉ុណ្ណោះ ដែលដឹងថាផ្ទះខ្ញុំមានរូបថតទាំងអស់នេះ ព្រោះគាត់ធ្លាប់ចេញចូលផ្ទះខ្ញុំ។

តំណាងអយ្យការ លើកឡើងថា ពាក់ព័ន្ធទៅនឹងឯកសារភស្ដុតាង និងរូបថតដែលដាក់បង្ហាញនៅទីនេះ បើយើងមិនឱ្យគេធ្វើទេ គ្មានអ្នកណាគេនឹកឃើញមកធ្វើឱ្យយើងនោះទេ លុះត្រាតែយើងបញ្ជាឱ្យគេធ្វើ ទើបគេហ៊ានធ្វើឱ្យ កុំបាច់ឆ្លើយដោះសារ។ ចំពោះប្រកាសដំឡើងឋានន្តរស័ក្ដិនាយទាហាន និងអត្តសញ្ញាណប័ណ្ណកងទ័ព ដែលជនជាប់ចោទបានក្លែងបន្លំនោះ គឺដើម្បីទាញយកផលប្រយោជន៍ ក្នុងគោលដៅឆបោកយកប្រាក់ពីឈ្មោះ [redacted] ធី ឱ្យគ្រប់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ ដោយសារតែជនរងគ្រោះទើបតែប្រគល់ប្រាក់ឱ្យខ្លួនចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ ។ ខ្លួនជារូបវន្តបុគ្គល មិនមែនជាស្ថាប័ននីតិសាធារណៈឯណា ប៉ុន្តែដើម្បីយកប្រាក់ពីអ្នកដទៃ ហ៊ានតាំងខ្លួនឯងជាឧត្ដមសេនីយ៍ទោ ដើរឆបោកប្រាក់ពីគេ ឱ្យគ្រួសារគេឈឺចាប់ និងរងទុកលំបាកដោយសារយើង ថែមទាំងធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ក្រសួងការពារជាតិ ព្រមទាំងធ្វើឱ្យមេកប្លាក្ដុស្រុសអគ្គិភ័ព និងបាត់បង់ទំនុកចិត្តរវាងកងទ័ព និងប្រជាជន។ រីឯអាវុធវិញ គឺមានចេតនាលាក់ទុកសម្រាប់ប្រើប្រាស់ ពីព្រោះនៅពេលដែលសមត្ថកិច្ចចូលឆែកឆេរឃើញថា អាវុធដាក់នៅបន្ទប់ដេក មិនឆ្លាតនៅផ្ទះឬបើ

ហើយគ្រាប់ដាក់នៅថតតុ ដែលការទុកដាក់នេះមានគោលបំណងចង់លាក់បាំង និងរក្សាទុកអាវុធ។ បើសិនជាមានចេតនាយកអាវុធទៅប្រគល់ឱ្យអង្គភាពវិញ គេត្រូវរៀបចំដាក់ វេចខ្ចប់យ៉ាងត្រឹមត្រូវ និងស្រួលបួល មិនមែនទុកដាក់រាយប៉ាយទេ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធី បានឆ្លើយថា ខ្ញុំស្គាល់ឈ្មោះ [redacted] រ៉ុងណាយ តាមរយៈកូនប្រុសរបស់ខ្ញុំ ([redacted] សំបូរ) ជាអ្នកនាំមកជួបគ្នា ហើយបាននិយាយរឿងការងារដែលកូនប្រុសខ្ញុំចង់ចូលធ្វើទាហាន ពេលនោះឈ្មោះ [redacted] រ៉ុងណាយ បានប្រាប់ខ្ញុំថាគាត់ស្គាល់គេម្នាក់ពាក់ផ្កាយ២ ចាំគាត់នាំខ្ញុំឱ្យទៅជួបគេ។ ក្រោយមកគាត់ក៏នាំខ្ញុំ និងកូនប្រុសរបស់ខ្ញុំ ([redacted] សំបូរ) ទៅជួបឈ្មោះ [redacted] ប៊ុនធឿន ហើយក៏បាននិយាយគ្នា ដោយត្រូវរ៉ូវគ្នាក្នុងតម្លៃ ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ ។ បន្ទាប់មកខ្ញុំបានប្រគល់ប្រាក់ទៅឱ្យឈ្មោះ [redacted] ប៊ុនធឿន ចំនួន ០៥ (ប្រាំ) លើក សរុបប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ ក្រោយមកឈ្មោះ [redacted] ប៊ុនធឿន បានប្រគល់ប្រកាសរបស់ក្រសួងការពារជាតិ និងអត្តសញ្ញាណប័ណ្ណកងទ័ព ឱ្យមកខ្ញុំ និងកូនប្រុសខ្ញុំ។

លោកមេធាវីបានសួរដេញដោលឈ្មោះ [redacted] ធី បានឆ្លើយថា ឈ្មោះ វ៉ាន់ រ៉ុងណាយ បាននាំខ្ញុំទៅជួបជាមួយឈ្មោះ [redacted] ប៊ុនធឿន ដើម្បីនិយាយគ្នារឿងពឹងពាក់គាត់ជួយរត់ការឱ្យកូនប្រុសរបស់ខ្ញុំឈ្មោះ [redacted] សំបូរ ចូលធ្វើទាហាន ដោយបានជួបគ្នានៅហាងចំការននោង។ ទឹកប្រាក់ដែលខ្ញុំបានប្រគល់ឱ្យឈ្មោះ [redacted] ប៊ុនធឿន ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ ដោយកូនប្រុសខ្ញុំ (នុត សំបូរ) ជាអ្នកធ្វើកិច្ចសន្យាប្រគល់ប្រាក់ ដែលលិខិតនេះកូនប្រុសខ្ញុំជាអ្នកសរសេរ។ បច្ចុប្បន្ន ខ្ញុំធ្វើការខាងរដ្ឋបាលសង្កាត់ព្រៃឈើខេត្តកំពត ខ្ញុំក៏ដឹងដែរថា ការជ្រើសរើសទាហាន គឺគេរើសតាមការប្រឡងប្រជែង ហើយការធ្វើកិច្ចសន្យាខ្ចីប្រាក់ គឺជារឿងស្របច្បាប់ ប៉ុន្តែមូលហេតុដែលក្នុងកិច្ចសន្យានេះមិនសរសេររត់ការចូលធ្វើទាហាន ព្រោះវាខុសច្បាប់។

តំណាងអយ្យការ បានលើកឯកសារលេខ ១៤/១ មកបង្ហាញ និងអានខ្លឹមសារក្នុងកិច្ចសន្យានេះ បន្ទាប់មកតំណាងអយ្យការបានបញ្ជាក់ថា ធម្មតាអ្នកដែលមានគំនិតឆបោកគេ មិនដែលទៅសរសេរលិខិតខ្លួនឯងនោះទេ គឺអ្នកដែលត្រូវគេបោកទេដែលជាអ្នកសរសេរកិច្ចសន្យា ព្រោះតែខ្លាចចាញ់បោកគេ ទើបសរសេរកិច្ចសន្យាទុកធ្វើភស្តុតាងសម្រាប់ថ្ងៃក្រោយ។ រីឯអ្នកដែលមានបំណងបោកប្រាសគេវិញ គឺមិនដែលទៅសរសេរថា ខ្ញុំបាទ ឧត្តមសេនីយ៍ទោ [redacted] ប៊ុនធឿន បានទទួលប្រាក់ចំនួននេះ ដើម្បីរត់ការឱ្យឈ្មោះនេះចូលធ្វើទាហាន គឺមិនមែនបែបនឹងទេ។ ជនជាប់ចោទមានចេតនាទុច្ចរិតក្នុងការឆបោករួចជាស្រេច ដោយមានបំណងបង្កើតកិច្ចសន្យាបិទបាំងជនរងគ្រោះ និងចេតនាធ្វើឱ្យមានការភាន់ច្រឡំ។ ដូច្នេះ កិច្ចសន្យានេះវាមានវិការៈនៅក្នុងនឹង ដែលវាមិនមែនជាកិច្ចសន្យារដ្ឋប្បវេណីទេ វាជាកិច្ចសន្យាបិទបាំងអំពើខុសច្បាប់។

ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយឈ្មោះ នុត សំបូរ បានឆ្លើយថា នៅក្នុងឆ្នាំ២០១៩ ខ្ញុំបានស្គាល់ឈ្មោះ [redacted] រ៉ុងណាយ ជាទាហាននៅបញ្ជាការដ្ឋានកងទ័ពជើងគោក ហើយខ្ញុំក៏បាននិយាយប្រាប់គាត់រឿងខ្ញុំចង់ចូលធ្វើទាហានដែរ និងបានសួរគាត់ថាតើគាត់អាចជួយខ្ញុំបានដែរឬទេ? គាត់ឆ្លើយថា ចាំគាត់ទៅពឹងពាក់ ឧត្តមសេនីយ៍ទោ [redacted] ប៊ុនធឿន ដែលធ្វើការនៅក្រសួងការពារជាតិឱ្យជួយ។ ក្រោយមកឈ្មោះ [redacted] រ៉ុងណាយ បានទូរស័ព្ទមកប្រាប់ខ្ញុំថាឈ្មោះ [redacted] ប៊ុនធឿន អាចជួយបាន ប៉ុន្តែដើម្បីរត់ការធ្វើ

ធ្វើទាហានស័ក្តិ៣ តម្រូវយកប្រាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារ ហើយខ្ញុំតថ្លៃជាមួយគាត់ ដោយព្រមព្រៀងគ្នាក្នុងតម្លៃ ១៤.០០០ (មួយម៉ឺនបួនពាន់) ដុល្លារ។ បន្ទាប់មកបានណាត់ជួបគ្នាជាមួយ ឈ្មោះ [redacted] ប៊ុនធឿន ចំនួន ០៥ ដងគឺ លើកទី១ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ លោក [redacted] ប៊ុនធឿន បានយកប្រាក់ពីខ្ញុំចំនួន ៤.០០០ (បួនពាន់) ដុល្លារ, លើកទី២ ចំនួន ៤.០០០ (បួនពាន់) ដុល្លារ, លើកទី៣ ចំនួន ១.០០០ (មួយពាន់) ដុល្លារ, លើកទី៤ ចំនួន ៥០០ (ប្រាំរយ) ដុល្លារ, ការជួបគ្នា៤លើកនេះ គឺនៅហាងចំការននោងភ្នំពេញ និងលើកទី៥ ឈ្មោះ [redacted] ប៊ុនធឿន បានទូរស័ព្ទហៅខ្ញុំឱ្យទៅជួបគ្នានៅម្តុំការ៉ាសាំងប៉ាប៉ា ក្បែរផ្សារអង្គតាសោម ខេត្តតាកែវ។ ពេលនោះ ខ្ញុំឃើញគាត់ស្លៀកពាក់ឯកសណ្ឋានយោធាពាក់ស័ក្តិផ្កាយ២ ជិះរថយន្តម៉ាកលុចស៊ីស (LEXUS350) ពណ៌ទឹកប្រាក់ ហើយគាត់ក៏ប្រគល់អត្តសញ្ញាណប័ណ្ណកងទ័ព និងប្រកាសស័ក្តិ៣ មកឱ្យខ្ញុំ ស្អែកឡើងខ្ញុំផ្ញើប្រាក់តាមវីងចំនួន ៥០០ (ប្រាំរយ) ដុល្លារ ទៅឱ្យគាត់។ សរុបទាំង៥លើក គាត់បានយកប្រាក់ពីខ្ញុំចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារ ហើយឯកសារដែលគាត់បានប្រគល់មកឱ្យខ្ញុំនោះ គឺសុទ្ធតែជាក្រដាសថតចម្លង។ ក្រោយមក នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ឈ្មោះ [redacted] ប៊ុនធឿន បានទាក់ទងមកប្រាប់ខ្ញុំថា ដោយសារតែជំងឺកូវីដ-១៩ ឆ្នាំនេះគេមិនរើសទាហានទេ ដល់ពេលគេរើសទាហានថ្មីចាំគាត់ដាក់ឈ្មោះឱ្យ បើមិនបានចូលធ្វើទាហានទេ គាត់នឹងសងប្រាក់មកឱ្យខ្ញុំវិញ ដោយសារពេលវេលាចេះតែយូរទៅៗ ខ្ញុំក៏សម្រេចចិត្តទាក់ទងទៅគាត់ដើម្បីយកប្រាក់វិញ ប៉ុន្តែខ្ញុំទាក់ទងគាត់មិនបាននោះទេ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីផូ បានឆ្លើយថា ខ្ញុំស្គាល់ឈ្មោះ [redacted] ប៊ុនធឿន តាមរយៈកូនស្រីរបស់ខ្ញុំឈ្មោះ [redacted] បុប្ផា ជាអ្នកណែនាំប្រាប់ថាឈ្មោះ [redacted] ប៊ុនធឿន ធ្វើការនៅក្រសួងការពារជាតិ មានតួនាទី និងឋានៈឧត្តមសេនីយ៍ពាក់ផ្កាយ២ ហើយគាត់បានធានាអះអាងថា អាចជួយកូនប្រុសខ្ញុំឱ្យចូលក្របខ័ណ្ឌក្រសួងការពារជាតិ ខាងទាហានជើងទឹក។ ក្រោយមកគាត់ទៅបាត់ដំបង ហើយគាត់ក៏បានឈៀងចូលទៅលេងផ្ទះខ្ញុំ ដើម្បីនិយាយរឿងរត់ការឱ្យកូនប្រុសខ្ញុំឈ្មោះ [redacted] រដ្ឋា ចូលធ្វើទ័ព ពេលនោះគាត់ប្រាប់ខ្ញុំថា មានយោធាផ្កាយ២នៅក្រសួងការពារជាតិអាចជួយបាន ហើយគាត់ក៏ជាឧត្តមសេនីយ៍ដែរ ពាក់ផ្កាយ២ មានឡានជិះ មានឯកសណ្ឋានយោធា ហើយផ្លាកលេខឡានខេមរភូមិន្ទទៀត ទាំងអស់នេះហើយដែលធ្វើឱ្យខ្ញុំជឿជាក់លើគាត់ទាំងស្រុង និងមានទំនុកចិត្ត។ គាត់បានប្រាប់ខ្ញុំថា នៅខាងទាហានជើងទឹកមានគេរើសទាហាន គេយកថ្លៃ ៨.០០០ (ប្រាំបីពាន់) ដុល្លារ បន្ទាប់មកខ្ញុំក៏ទៅលក់ដីនៅខេត្តកំពង់ស្ពឺ បានប្រាក់ចំនួន ១៣.០០០ (មួយម៉ឺនបីពាន់) ដុល្លារ ដោយឱ្យឈ្មោះ [redacted] ប៊ុនណា ផ្ញើតាម ABA (អេប៊ីអេ) ទៅឱ្យឈ្មោះ [redacted] ប៊ុនធឿន នៅខាងក្រោយក្រសួងកិច្ចការនារី នូវទឹកប្រាក់ចំនួន ១២.៧០០ (មួយម៉ឺនពីរពាន់ប្រាំពីររយ) ដុល្លារ ហើយគាត់ក៏ប្រាប់ខ្ញុំវិញថា គេយកតែ ៨.០០០ (ប្រាំបីពាន់) ដុល្លារ ទេ ប៉ុន្តែប្រាក់នៅសល់ឈ្មោះ [redacted] ប៊ុនធឿន មិនបានបង្វិលឱ្យខ្ញុំវិញឡើយ ហើយក្រោយមកទៀតខ្ញុំបានផ្ញើប្រាក់ចំនួន ២.៤០០ (ពីរពាន់បួនរយ) ដុល្លារ បន្ថែមឱ្យគាត់។ ចំពោះរឿងប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារ ខ្ញុំមិនបានដឹងនោះទេ ប៉ុន្តែខ្ញុំដឹងថាកូនស្រីខ្ញុំគ្មានប្រាក់នោះទេ ហើយចំពោះរឿងដែលឈ្មោះ [redacted] ប៊ុនធឿន ឆ្លើយថាបានសងប្រាក់មកខ្ញុំខ្លះនោះ គឺខ្ញុំមិនដែលបានទទួលទេ បើសិនជាគាត់បានសងវិញមែន សូមឱ្យគាត់បង្ហាញភស្តុតាងមកៗ

លោកមេធាវី សួរដេញដោលឈ្មោះ [redacted] ស៊ីផូ បានឆ្លើយថា កូនស្រីរបស់ខ្ញុំឈ្មោះ [redacted] បុប្ផា ធ្វើទាហាននៅអង្គភាពកំចាត់មីនស៊ីម៉ាក់ ជាអ្នកណែនាំឱ្យខ្ញុំស្គាល់គ្នាជាមួយឈ្មោះ [redacted] ប៊ុនធឿន ហើយបច្ចុប្បន្ន កូនស្រីខ្ញុំកំពុងមានបេសកកម្មនៅក្រៅប្រទេស។ កូនស្រីខ្ញុំស្គាល់គាត់ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ហើយដំបូងឡើយកូនស្រីខ្ញុំជាអ្នកពឹងពាក់គាត់ជួយរត់ការឱ្យប្អូនប្រុសវា ប៉ុន្តែកូនស្រីខ្ញុំអត់មានប្រាក់នោះទេ ហើយក្រោយមកវាក៏ចេញទៅក្រៅប្រទេសបាត់ទៅ ដោយកូនស្រីខ្ញុំទាក់ទងគាត់តាមទូរស័ព្ទពីក្រៅប្រទេសមក។ កូនស្រីខ្ញុំបានប្រាប់ខ្ញុំថាឈ្មោះ [redacted] ប៊ុនធឿន ធ្វើការនៅក្រសួងការពារជាតិ មានតួនាទី និងឋានៈឧត្តមសេនីយ៍ទោ។ ពេលដែលខ្ញុំបានស្គាល់គាត់រយៈពេលប្រហែលជា ០១ (មួយ) ខែ ក្រោយមក គាត់ក៏ប្រាប់ខ្ញុំថា ឱ្យរកប្រាក់ និងរៀបចំឯកសារដើម្បីទៅដាក់ពាក្យប្រឡងនៅទាហានជើងទឹកជ្រោយចង្វារ។ ពេលដែលគាត់ទៅលេងផ្ទះខ្ញុំ គាត់ជិះរថយន្តពាក់ផ្លាកលេខខេមរភូមិន្ទ ពាក់ឯកសណ្ឋានយោធាផ្កាយ២ នៅលើស្មា ហើយពេលខ្លះគាត់ព្យួរអាវទុកក្នុងរថយន្ត។ ដោយសារតែគាត់ធានាអះអាងថា គាត់ធ្វើការនៅក្រសួងការពារជាតិ គាត់ពាក់ស័ក្តិផ្កាយ២ គាត់ស្គាល់អ្នកនៅក្រសួងការពារជាតិ និងធានារត់ការឱ្យចូលទ័ពបាន ទើបធ្វើឱ្យខ្ញុំជឿទុកចិត្តទៅលើរូបគាត់ ហើយសុខចិត្តទៅលក់ដី យកប្រាក់ប្រគល់ឱ្យគាត់ និងបានឱ្យកូនប្រុសទៅដាក់ពាក្យប្រឡងចូលទ័ពជើងទឹកតាមសម្តីរបស់គាត់ ប៉ុន្តែមិនបានសម្រេចទេ។ ចំពោះការយកប្រាក់ទៅឱ្យគេដើម្បីរត់ការចូលទ័ព វាជាអំពើដែលច្បាប់ហាមឃាត់ ពីព្រោះការជ្រើសរើសទ័ព មិនតម្រូវឱ្យដាក់ប្រាក់ដើម្បីជាប់នោះទេ គឺធ្វើឡើងដោយការប្រឡងប្រជែង ប៉ុន្តែដោយសារតែបរិបទសង្គមមានការប្រែប្រួល ទើបខ្ញុំហ៊ានធ្វើបែបនេះ។

ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយឈ្មោះ [redacted] ជិននិមល បានឆ្លើយថា ខ្ញុំស្គាល់ឈ្មោះ [redacted] ប៊ុនធឿន តាមរយៈអ្នកធ្វើការនៅក្នុងអង្គភាពជាមួយគ្នា ហើយគាត់បាននាំខ្ញុំឱ្យទៅជួបឈ្មោះ [redacted] ធ្វើការនៅក្រសួងការពារជាតិ។ បន្ទាប់មកឈ្មោះ [redacted] បាននាំខ្ញុំឱ្យទៅជួបឈ្មោះ [redacted] ប៊ុនធឿន នៅហាងកាហ្វេអាម៉ាហ្សូនវត្តភ្នំ ដែលពេលនោះខ្ញុំឃើញឈ្មោះ សុខ ប៊ុនធឿន ស្លៀកពាក់ឯកសណ្ឋានយោធា ពាក់ផ្កាយ២ ហើយខ្ញុំបានសួរនាំគាត់រឿងខ្ញុំចង់ដូរអង្គភាពការងារពីទាហានជើងទឹក ទៅទាហានជើងគោកនៅភូមិភាគពិសេស តើគាត់អាចជួយបានដែរឬទេ? គាត់ឆ្លើយថា គាត់អាចដូរឱ្យបានដោយយកប្រាក់ថ្លៃរត់ការ ហើយបានឯកភាពគ្នាក្នុងតម្លៃ ៣.៥០០ (បីពាន់ប្រាំរយ) ដុល្លារ។ ការប្រគល់ប្រាក់ធ្វើឡើង ០៣ ដំណាក់កាលគឺ លើកទី១ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ ឈ្មោះ [redacted] ប៊ុនធឿន បានទទួលប្រាក់ពីខ្ញុំចំនួន ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារ, លើកទី២ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ គាត់បានទទួលប្រាក់ពីខ្ញុំចំនួន ១.០០០ (មួយពាន់) ដុល្លារ, និងលើកទី៣ គឺសន្យាគ្នាថាដល់រត់ការបានសម្រេច ចាំប្រគល់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារ បន្ថែមទៀត ប៉ុន្តែបើសិនជារត់ការមិនបានសម្រេចនោះទេ គាត់នឹងសងប្រាក់ឱ្យខ្ញុំវិញ។ ក្រោយពេលដែលគាត់បានទទួលប្រាក់ពីខ្ញុំចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លារ រួចហើយ ខ្ញុំទាក់ទងគាត់លែងបាន ហើយក្រោយមកខ្ញុំទទួលដំណឹងថាឈ្មោះ [redacted] ប៊ុនធឿន ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបញ្ជូនមកតុលាការយោធា ទើបខ្ញុំចូលមកប្តឹងទាមទារប្រាក់សំណងវិញ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធី បានសំណូមពរថា សូមតុលាការយោធាជួយឱ្យឈ្មោះ [redacted] ប៊ុនធឿន សងប្រាក់មកខ្ញុំវិញគ្រប់ចំនួន។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីផូ បានសំណូមពរថា សូមតុលាការឃោជាជួយឱ្យឈ្មោះ [redacted] ប៊ុនធឿន សងប្រាក់មកនាងខ្ញុំវិញ ចំនួន ៨០% នៃប្រាក់ដែលគាត់បានទទួលពីនាងខ្ញុំ។

តំណាងអយ្យការអមតុលាការឃោជា ឡើងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ទោសថា ឆ្លងតាមការសួរដេញដោល ចំពោះអង្គសវនាការ និងការពិភាក្សាគ្នាទៅលើឯកសារភស្តុតាងនានា ដែលមានដាក់បង្ហាញនៅទីនេះ ឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើទាំងអស់នេះប្រាកដមែន។ ខ្ញុំ [redacted] ហុង ក្នុងនាមជាតំណាងអយ្យការអមតុលាការឃោជា សូមរក្សាការចោទប្រកាន់ទុកជាបានការដដែល និងស្នើសុំឱ្យតុលាការឃោជា ផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ឱ្យបានធ្ងន់ធ្ងរបំផុតតាមកំណត់ច្បាប់។

មេធាវីការពារក្តីឱ្យជនជាប់ចោទ បានលើកឡើងថា ក្នុងនាមខ្ញុំជាមេធាវីការពារក្តីឱ្យជនជាប់ចោទ មុននឹងធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តី ខ្ញុំសូមរំលេចទៅលើអង្គហេតុ និងអង្គច្បាប់នៅក្នុងសំណុំរឿងបន្តិចសិន។ ឆ្លងតាមការសួរដេញដោលក្នុងអង្គសវនាការនាថ្ងៃនេះ យើងបានឃើញ បានដឹង បានឮទាំងអង្គសវនាការ ទាំងភ្ញៀវចូលរួមក៏បានស្តាប់ និងបានឃើញនូវអ្វីដែលពាក់ព័ន្ធក្នុងរឿងហេតុដូចជាម្នាក់ៗសុទ្ធតែមាន ឯកសារភស្តុតាងយកមកបញ្ជាក់ជូនតុលាការ ប៉ុន្តែដោយឡែកចម្លើយមួយចំនួនរបស់កូនក្តីខ្ញុំ គឺពុំមានភស្តុតាងមកបញ្ជាក់នោះទេ ហើយភស្តុតាងដែលភាគីបានលើកយកមកនោះ ក៏មិនសូវមានភាពច្បាស់លាស់ដែរ នាំឱ្យយើងពិបាកក្នុងការពិចារណា។ យោងតាមអង្គហេតុនៃរឿង ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ សុទ្ធតែបានដឹងហើយថា ការយកប្រាក់រត់ការចូលទ័ព ការយកប្រាក់រត់ការដើម្បីប្រឡងចូលទ័ព និងយកប្រាក់ទៅរត់ការផ្លាស់ប្តូរអង្គភាព សុទ្ធតែជាអំពើខុសច្បាប់ ប៉ុន្តែពួកគាត់នៅតែបំពានច្បាប់។ អង្គហេតុនេះ វាស្តែងឱ្យឃើញថាមិនមែនជារឿងឆបោកប្រាក់នោះទេ ប៉ុន្តែវាបង្ហាញអំពីការយកប្រាក់ទៅសូកប៉ាន់ ដើម្បីឱ្យគេបំពេញកាតព្វកិច្ចមកឱ្យខ្លួនវិញ ហើយការសូកប៉ាន់គឺជារឿងពុករលួយ ដែលអំពើពុករលួយមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ហើយមាននៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ពាក់ព័ន្ធទៅនឹងកិច្ចសន្យា គឺជារឿងរដ្ឋប្បវេណី មិនមែនជារឿងព្រហ្មទណ្ឌទេ ព្រោះខ្លឹមសារនៅក្នុងលិខិត មិនបានសរសេរថាជាកិច្ចសន្យារត់ការចូលធ្វើទាហានឡើយ ដោយសារតែនៅក្នុងខ្លឹមសារ គឺសរសេរថាជាកិច្ចសន្យាខ្ចីប្រាក់។ ដូចនេះ វាជារឿងវិវាទលើកិច្ចសន្យាទាំងស្រុង ដើមបណ្តឹងគួរតែប្តឹងទាមទារសំណងរដ្ឋប្បវេណី ក្នុងរឿងស៊ីវិល មិនគួរប្តឹងទៅតុលាការព្រហ្មទណ្ឌក្នុងរឿងឆបោកនោះទេ។ បើទាក់ទងនឹងការឆបោក គឺមិនសមហេតុផលទេ ដោយសារតែកូនក្តីខ្ញុំមិនបានទៅលួងលោម ឬដាក់សំណើឡើយ តើអ្នកណាលួងលោមអ្នកណា? តើអ្នកណាបោកបញ្ឆោតអ្នកណា? ព្រោះដើមបណ្តឹងខ្លួនឯងទេតើ ដែលជាអ្នកមកសុំពឹងពាក់កូនក្តីខ្ញុំឱ្យជួយពួកគាត់។ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ របស់តំណាងអយ្យការ គឺមិនត្រឹមត្រូវតាមអង្គហេតុដែលបានកើតឡើងឡើយដូចជា ការប្រើប្រាស់ឯកសណ្ឋាន ការប្រើយានៈណាមួយ និងការរក្សាអាវុធទុកក្នុងផ្ទះជាដើម កូនក្តីខ្ញុំមិនបានឆបោកគេនោះទេ ហើយមិនបានទៅធ្វើសកម្មភាពឆក់ប្លន់នរណានោះដែរ។ ចំពោះការថតរូប ការតុបតែងរូបផ្សេង និងឯកសារផ្សេងទៀត គ្រាន់តែសម្រាប់ដាក់តាំងនៅក្នុងផ្ទះតែប៉ុណ្ណោះ តើអំពើនេះពិតជាមានទោសមែនទេ? តើច្បាប់ពិតជាតម្រូវឱ្យដាក់ទោសដែរឬយ៉ាងណា? ចំពោះរឿងក្លែងបន្លំឯកសារសាធារណៈ យើងត្រូវសួរថា តើធ្វើបៀបណា ដែលគេចាត់ទុកថាជាការក្លែងបន្លំលើលិខិតយថាភូតមួយចំនួនខ្ញុំគ្មាន

លក្ខណៈផ្លូវច្បាប់ ឬលិខិតចេញដោយរាជការសាធារណៈ បើគ្រាន់តែជាការកាត់តអត្តសញ្ញាណប័ណ្ណកងទ័ព និងកាត់តប្រកាសដំឡើងឋានន្តរស័ក្តិជាដើម។

មេធាវីការពារក្តីឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ឆ្លងតាមការវែកញែកទាំងអង្គហេតុ និងអង្គច្បាប់ដែលខ្ញុំបានបង្ហាញខាងលើ ខ្ញុំសូមធ្វើការសន្និដ្ឋានការពារដូចតទៅ ការចោទប្រកាន់មកលើកូនក្តីខ្ញុំពីបទឆបោក គឺមិនត្រឹមត្រូវនោះទេ ព្រោះរឿងនេះគឺជាការសូកប៉ាន់មកលើកូនក្តីខ្ញុំ ដែលជារឿងអំពើពុករលួយ ជាបទល្មើសពុករលួយមានចែងក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ។ អំពើដែលជនរងគ្រោះបានយកប្រាក់ទៅឱ្យកូនក្តីរបស់ខ្ញុំ ដើម្បីបំពេញកាតព្វកិច្ចឱ្យពួកគាត់ គឺជារឿងសូកប៉ាន់យ៉ាងពិតប្រាកដ សូមឱ្យតុលាការពិចារណា ធ្វើការចោទប្រកាន់ទៅលើដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ពីបទសូកប៉ាន់។ បើមិនចោទប្រកាន់ទេ សូមឱ្យកូនក្តីរបស់ខ្ញុំរួចផុតពីបទឆបោក ហើយសុំឱ្យតុលាការយោធាពិចារណា ទៅលើបទក្លែងបន្លំឯកសារសាធារណៈ ទៅជាបទប្រើប្រាស់ឯកសារក្លែងវិញ ដោយធ្វើការកែប្រែបទចោទពីមាត្រា៦១៧ ទៅមាត្រា៦១៩, មាត្រា៦២៩ ទៅមាត្រា៦៣០ និងមាត្រា៣៧៧ ទៅមាត្រា៥៩៤, ៦០៥ ដោយចោទប្រកាន់លើដើមបណ្តឹងរដ្ឋប្បវេណីផង។

តំណាងអយ្យការ បានលើកឡើងថា ក្រោយពីបានស្តាប់ការវែកញែក និងការសំណូមពររបស់លោកមេធាវីរួចហើយ គឺវាផ្ទុយស្រឡះទៅនឹងអ្វីដែលតំណាងអយ្យការបានចោទប្រកាន់។ ការដែលលោកមេធាវីលើកយកមាត្រា៥៩៤ និងមាត្រា៦០៥ មកនិយាយ គឺមិនត្រឹមត្រូវទាល់តែសោះ លុះត្រាតែកូនក្តីរបស់លោកមេធាវីជាអ្នករាជការសាធារណៈ ឬជានាយទាហាន ទើបជារឿងអំពើពុករលួយ រឿងស៊ីសំណូកសូកប៉ាន់ ប៉ុន្តែកូនក្តីរបស់លោកមេធាវីគឺជាជនអាវ៉ាសែ ដើរបោកប្រាស់គេ ធ្វើឱ្យគេរងទឹកភ្នែក មានចេតនាប្រើប្រាស់កិច្ចសន្យាបំភាន់ ដើម្បីឆបោកប្រាក់ពីគេ រឿងអ្វីដែលមិនមែនជាការឆបោក បើយកប្រាក់ពីគេរាប់ម៉ឺនដុល្លារហើយនឹង។ ក្រោយពីយកប្រាក់ពីគេរួចហើយ កូនក្តីរបស់លោកបានទៅកាត់តក្លែងបន្លំប្រកាសរបស់ក្រសួងការពារជាតិ និងកាត់តក្លែងបន្លំអត្តសញ្ញាណប័ណ្ណរបស់កងទ័ព អត់មាននៅក្នុងគល់បញ្ជីរបស់ក្រសួងការពារជាតិ ហើយយកទៅប្រគល់ឱ្យគេ ដើម្បីបិទបាំងបទល្មើសរបស់ខ្លួន។ ទង្វើរនេះបើមិនហៅថាក្លែងបន្លំឯកសារសាធារណៈ តើគេហៅថាជាទង្វើរអ្វីទៅវិញ? ហើយឯកសារទាំងអស់នឹង បើខ្លួនមិនបានបញ្ជាឱ្យគេធ្វើទេ គឺគ្មាននរណាគេហ៊ានធ្វើឱ្យយើងទេ ដូចនេះ ការសំណូមពរឱ្យក្រុមប្រឹក្សាជំនុំជម្រះ កែប្រែមាត្រាចោទគឺមិនត្រឹមត្រូវឡើយ។ ចំពោះរឿងអាវុធវិញ បើខ្លួនមានចេតនា និងមានឆន្ទៈយកទៅប្រគល់ឱ្យគេមែន ខ្លួនត្រូវរៀបចំទុកដាក់ឱ្យបានត្រឹមត្រូវ ប៉ុន្តែការទុកដាក់អាវុធនេះបានស្តែងឱ្យឃើញចេតនាថា ខ្លួនគ្មានឆន្ទៈក្នុងការប្រគល់ត្រឡប់ទៅវិញទេ ដោយមានចេតនារក្សាទុកសម្រាប់គោលបំណងអួតអាង និងសម្លែងដល់អ្នកដទៃ ក្នុងការទាញយកផលប្រយោជន៍ណាមួយ។ សូមតុលាការពិចារណាឱ្យបានហ្មត់ចត់ចំពោះការលើកឡើង និងស្នើសុំរបស់មេធាវី។

មេធាវីការពារក្តីឱ្យជនជាប់ចោទ បានលើកឡើងថា អង្គហេតុ និងបទល្មើសទាំងអស់នេះ ចំពោះអំពើពុករលួយ គឺមិនដូចទៅនឹងការលើកឡើង របស់តំណាងអយ្យការនោះទេ។ មាត្រា៥៩៤ និងមាត្រា៦០៥ (បទសូកប៉ាន់ និងបទស៊ីសំណូក) គឺមិនសម្តៅទៅលើអ្នករាជការសាធារណៈ ឬបុគ្គលដែលមានឋានៈណានោះទេ គឺសម្តៅទៅដល់គ្រប់បុគ្គលទាំងអស់ ទោះបីជាបុគ្គលណាក៏ដោយ ប្រភេទណាក៏ដោយ។

ហេតុដូចនេះ សំណូមពរឱ្យតុលាការ កែប្រែបទចោទទាំងអស់ខាងលើ ដែលតំណាងអយ្យការអមតុលាការយោធា បានចោទប្រកាន់មកលើកូនក្តីរបស់ខ្ញុំ។

- ក្រោយពីបានសួរដេញដោលចំពោះមុខក្នុងអង្គសវនាការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ
- ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការអមតុលាការយោធា
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវី
- ក្រោយពីបានស្តាប់ការសួរសំណួរដេញដោល របស់តំណាងអយ្យការ មេធាវី ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់រួចរាល់ហើយ

## តុលាការយោធាយល់ឃើញថា

ជនជាប់ចោទឈ្មោះ[redacted]ប៊ុនធឿន ភេទប្រុស អាយុ ៤១ ឆ្នាំ មុខរបរគក់ដេដី និងគក់ដេឡាន ពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើស ដោយសម្អាងហេតុថា មានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ មានចម្លើយសារភាពរបស់ជនជាប់ចោទ ព្រមទាំងភស្តុតាងនានា ដែលសមត្ថកិច្ចរឹបអូសបាន និងដកហូតបានជាក់ស្តែងពីជនជាប់ចោទ។[redacted] សុខ ប៊ុនធឿន បានប្រព្រឹត្តកន្លងមក បានស្តែងឱ្យឃើញនូវជាតុសត្យានុម័ត និងអត្តនោម័តរបស់ជនជាប់ចោទ ដែលបានបង្កើតឡើងបង្កប់នូវចេតនាទុច្ចរិតក្នុងសកម្មភាពខុសច្បាប់ ព្រោះជនជាប់ចោទបានអះអាងទៅលើឋានៈក្លែង វិលោភលើឋានៈពិតប្រាកដ ឃោសនាបំផ្លិចបំផ្លាញ បំបែកបំបាក់ ធ្វើឱ្យមហាជន និងប្រជាពលរដ្ឋមានការភាន់ច្រឡំ ប៉ះពាល់ដល់ថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់កងយោធពលខេមរភូមិន្ទ នាំឱ្យបាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋ និងខូចប្រយោជន៍ដល់តតិយជន ដើម្បីបំពេញភាពលោភលន់ និងការចង់បានផលប្រយោជន៍ផ្ទាល់ខ្លួនឯងតែប៉ុណ្ណោះ ទោះបីជាខ្លួនបានដឹងថា អំពើដែលខ្លួនប្រព្រឹត្តនោះជាអំពើខុសច្បាប់ក៏ដោយ ក៏ខ្លួននៅតែប្រើមធ្យោបាយធ្វើឱ្យសម្រេចទាល់តែបានតាមឆន្ទៈរបស់ខ្លួន ដោយមិនគិតពីផលវិបាក ដែលនាំឱ្យអ្នកដទៃបាត់បង់ប្រយោជន៍នោះឡើយ។

យល់ឃើញថា ជនជាប់ចោទគឺជាជនស៊ីវិល ហើយបានបន្លំខ្លួនជានាយទាហាន ដោយស្លៀកពាក់ឯកសណ្ឋានយោធា មានឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ហើយដើរឆបោកប្រជាពលរដ្ឋឱ្យជឿជាក់មកលើខ្លួនថា ខ្លួនមានបុណ្យស័ក្តិខ្ពង់ខ្ពស់ ក្នុងការពឹងពាក់ឱ្យជួយរត់ការ បំពេញក្របខ័ណ្ឌក្នុងកងយោធពលខេមរភូមិន្ទ និងបានលាក់ទុកអាវុធ គ្រាប់រំសេវ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។ ដោយខ្លួនដឹងហើយថា ខ្លួនជាជនស៊ីវិល ប៉ុន្តែមានចេតនានៅតែលាក់អាវុធទុកប្រើប្រាស់ទៀត ដែលអំពើនេះផ្ទុយពីច្បាប់គ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ ពិតប្រាកដមែន។

យល់ឃើញថា ជនជាប់ចោទបានឆបោកប្រាក់ពីជនរងគ្រោះឈ្មោះ [redacted]ធី និង [redacted]សំបូរ, ឈ្មោះ [redacted]ស៊ីផូ និងឈ្មោះ [redacted]ជិននិមល ដោយបានធានាអះអាងក្នុងការជួយរត់ការធ្វើយោធា និងការផ្ទេរអង្គភាពកងទ័ពពិតប្រាកដមែន។

យល់ឃើញថា ជនជាប់ចោទបានដឹងច្បាស់ថា កាតព្វកិច្ចដែលត្រូវបំពេញឱ្យជនរងគ្រោះ នូវអ្វីដែលខ្លួនបានអះអាងធានាខុសត្រូវនោះ គឺមិនបានសម្រេចនោះទេ ប៉ុន្តែខ្លួនមានចេតនាគេចវេសពីការទទួលខុសត្រូវ ដោយបានធ្វើការក្លែងបន្លំឯកសារសាធារណៈរបស់ក្រសួងការពារជាតិ (អត្តសញ្ញាណប័ណ្ណនាយទាហាន និងប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិ នាយទាហាន នាយទាហានរង លេខ ៩០ តប់ស ០៣២០ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងការពារជាតិ) យកទៅប្រគល់ឱ្យជនរងគ្រោះ ដើម្បីបំភ័ន្តការពិត ក្នុងការគេចផុតពីការទទួលខុសត្រូវរបស់ខ្លួន។

យល់ឃើញថា អំពើរបស់ជនជាប់ចោទដែលបានធ្វើឡើងនេះ ផ្ទុយពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយខុសពីប្រកាស និងសេចក្តីសម្រេចរបស់ក្រសួងការពារជាតិ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្យានុភាព នៃកងយោធពលខេមរភូមិន្ទ ព្រោះថាជនជាប់ចោទមានកម្រិតវប្បធម៌ខ្ពស់ (ថ្នាក់បរិញ្ញាបត្រ) ប៉ុន្តែបែរជាទៅប្រព្រឹត្តអំពើរំលោភបំពានច្បាប់ទៅវិញ។

យល់ឃើញថា ជនជាប់ចោទបានដឹងយ៉ាងច្បាស់ថា អំពើដែលខ្លួនបានប្រព្រឹត្តនោះ គឺជាអំពើខុសច្បាប់ ប៉ុន្តែខ្លួននៅតែបន្តប្រព្រឹត្តដោយចេតនា ហើយគ្មានបំណងកែប្រែកំហុស និងគ្មានឆន្ទៈក្នុងការបញ្ឈប់ទង្វើរដោយខ្លួនឯងឡើយ។

យល់ឃើញថា ជនជាប់ចោទប្រព្រឹត្តបទល្មើសរួចហើយ មានគោលបំណងគេចវេសមិនទទួលខុសត្រូវនូវទង្វើររបស់ខ្លួន ដោយគ្មានឆន្ទៈក្នុងការបញ្ឈប់ និងមិនបានកែប្រែកំហុសរបស់ខ្លួននោះទេ ប៉ុន្តែបែរជាជនជាប់ចោទ ទៅប្រព្រឹត្តបទល្មើសថ្មីបន្ថែមមួយទៀត ដើម្បីបំភាន់ និងបិទបាំងទង្វើរខុសច្បាប់របស់ខ្លួនទៅវិញ។

យល់ឃើញថា អំពើដែលជនជាប់ចោទបានប្រព្រឹត្តនោះ បានបង្កឱ្យបាត់បង់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជះឥទ្ធិពលអាក្រក់ទៅដល់មហាជន និងសង្គមជាតិ ជាពិសេសនោះគឺ ធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ទំនុកចិត្ត ទៅលើថ្នាក់ដឹកនាំក្រសួងការពារជាតិ នាំឱ្យខូចភាពស្អាតស្អំរបស់ក្រសួងការពារជាតិ ព្រមទាំងប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់កងយោធពលខេមរភូមិន្ទ។

យល់ឃើញថា ការសួរដេញដោលចំពោះមុខ នៅក្នុងអង្គសវនាការ ជនជាប់ចោទឈ្មោះ [redacted]ប៊ុនធឿន បានព្យាយាមឆ្លើយដោះសារ មិនសារភាពកំហុស មានការលាក់លៀម និងឆ្លើយបង្វែងដានតុលាការ ដើម្បីគេចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់ ហើយទោះបីជាមានភស្តុតាងបង្ហាញច្បាស់លាស់យ៉ាងណាក៏ដោយ ក៏ជនជាប់ចោទនៅតែឆ្លើយបំភ្លៃការពិត ដោយគ្មានភស្តុតាងអ្វីទាំងអស់មកបញ្ជាក់ក្នុងការការពារចម្លើយរបស់ខ្លួន ជាក់ស្តែងជនជាប់ចោទឆ្លើយមិនសមហេតុផល និងឆ្លើយទម្លាក់កំហុសទៅលើឈ្មោះ [redacted]ឃាង ដែលបានស្លាប់បាត់បង់ជីវិតទៅហើយ។

យល់ឃើញថា ការសន្និដ្ឋានទោស និងការបង្ហាញភស្តុតាងនានា ព្រមទាំងការលើកឡើងរបស់តំណាងអយ្យការអមតុលាការយោធា ក្នុងពេលសវនាការមានសម្អាងហេតុត្រឹមត្រូវតាមផ្លូវច្បាប់ អាចឱ្យតុលាការយោធាយកមកពិចារណាបាន។

យល់ឃើញថា ការសន្និដ្ឋានការពាររបស់លោកមេធាវី [redacted] សុភាវុធ លើកឡើងក្នុងពេលសវនាការ មានចំណុចមួយចំនួន អាចឱ្យតុលាការយោធាពិចារណាបាន ប៉ុន្តែចំណុចមួយចំនួនទៀត មិនអាចឱ្យតុលាការយោធា យកមកពិចារណាបានទេ។

យល់ឃើញថា ជនជាប់ចោទមិនទាន់សងសំណងរដ្ឋប្បវេណី និងមិនបានដាក់ប្រាក់តម្កល់សម្រាប់ទូទាត់សំណងរដ្ឋប្បវេណី ទៅឱ្យជនរងគ្រោះនោះទេ។

យល់ឃើញថា ការកាត់តលិខិតផ្សេងៗ ការកាត់តវិញ្ញាបនបត្របញ្ជាក់ការសិក្សា ការកាត់តប័ណ្ណសរសើរ និងការកាត់តរូបថត ជាមួយថ្នាក់ដឹកនាំក្រសួងការពារជាតិ សម្រាប់ដាក់តាំងទុកមើលនៅក្នុងផ្ទះ មិនមែនជាទោសកំហុសធ្ងន់ធ្ងរនោះទេ។

យល់ឃើញថា ការស្លៀកពាក់ឯកសណ្ឋានយោធាដោយគ្មានសិទ្ធិ, ការក្លែងបន្លំខ្លួនជានាយទាហាន, ការអះអាងពីតួនាទីក្លែង និងការប្រើឋានៈក្លែង ក្នុងការទាញយកផលប្រយោជន៍អ្វីមួយ ធ្វើឱ្យតតិយជនជឿទុកចិត្ត ហើយព្រមប្រគល់នូវតម្លៃជាទ្រព្យសម្បត្តិ និងធ្វើឱ្យមានព្យសនកម្មដល់តតិយជន គឺជាបទល្មើសប្រាកដមែន។

យល់ឃើញថា ការកាត់តប្រកាសរបស់ក្រសួងការពារជាតិ និងការកាត់តអត្តសញ្ញាណប័ណ្ណរបស់នាយទាហាន ដើម្បីយកទៅបិទបាំងអំពើល្មើសណាមួយ គឺជាបទល្មើសប្រាកដមែន ប៉ុន្តែការក្លែងបន្លំឯកសារនេះ គ្រាន់តែជាឯកសារកាត់តថតចម្លង មិនមែនជាការក្លែងបន្លំឯកសារដោយការ ចុះហត្ថលេខាក្លែង និងការបោះត្រាក្លែង នៅលើឯកសារនោះទេ នាំឱ្យតុលាការយោធា អាចធ្វើការពិចារណាបាន។

យល់ឃើញថា ការរក្សាទុកអាវុធខ្លី បង់ និងគ្រាប់កាំភ្លើង នៅក្នុងផ្ទះដោយគ្មានលិខិតអនុញ្ញាត និងការកាន់កាប់អាវុធដោយគ្មានសិទ្ធិ គឺជាបទល្មើសប្រាកដមែន។

យល់ឃើញថា ជនជាប់ចោទបាននិយាយសម្តីចុងក្រោយថា ខ្ញុំបាទព្រមទទួលស្គាល់កំហុស សូមឱ្យតុលាការយោធាមេត្តាសម្រាលទោសឱ្យខ្ញុំបាទផង ដើម្បីឱ្យខ្ញុំបាទឆាប់មានសេរីភាពវិញនឹងឆាប់បានវិលត្រឡប់ទៅរស់នៅជួបជុំគ្រួសារ រកស៊ីចិញ្ចឹមប្រពន្ធកូន និងមើលថែឪពុកម្តាយចាស់ជរា។ ខ្ញុំបាទសូមសន្យាថា នៅពេលដែលខ្ញុំបានចេញទៅវិញ ខ្ញុំនឹងខិតខំកែប្រែកំហុស ព្រមទាំងកសាងខ្លួនឱ្យក្លាយជាកូនល្អ ប្តីល្អ ឪពុកល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

យល់ឃើញថា អំពើដែលជនជាប់ចោទបានប្រព្រឹត្តកន្លងមក គឺជាបទល្មើសព្រហ្មទណ្ឌ ត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## ហេតុដូច្នេះតុលាការយោធា
## សម្រេចវិនិច្ឆ័យសេចក្តី

ក. ការផ្តន្ទាទោស

ផ្តន្ទាទោសឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ ៤១ ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារចំនួន ០៥ (ប្រាំ) ឆ្នាំ ដោយទោសនេះត្រូវអនុវត្តដូចតទៅ:

១/. អនុវត្តទោសក្នុងពន្ធនាគារចំនួន ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃឃាត់ខ្លួន ០១ មីនា ២០២១។

២/. ទោសនៅសល់ព្យួរធម្មតា និងពិន័យជាប្រាក់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ចូលថវិកាជាតិ តាមមាត្រា១០៦, ១០៧, ១០៨ នៃក្រមព្រហ្មទណ្ឌ។

ពីបទ ប្រើប្រាស់ដោយខុសច្បាប់នូវសម្លៀកបំពាក់ជាអាទិ៍ សម្រាប់អាជ្ញាធរសាធារណៈ, ប្រើប្រាស់មិនប្រក្រតីឋានៈណាមួយ, ឆបោក, កាន់កាប់លាក់ទុកអាវុធគ្រាប់រំសេវដោយខុសច្បាប់, ទិញលាក់ទុក ប្រើប្រាស់ឋានន្តរស័ក្តិ និងក្លែងបន្លំឯកសារសាធារណៈ (ប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិ និងអត្តសញ្ញាណប័ណ្ណនាយទាហាន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ និងខេត្តកំពង់ធំ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា៣៧៧, ៣៧៨, ៦១២, ៦២០, ៦២៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ និងមាត្រា៨ នៃក្រឹត្យច្បាប់លេខ០៤ ស្តីពីបទល្មើសមានលក្ខណៈឃោរឃៅនិងទណ្ឌកម្ម។

ខ. ប្រាក់សំណងរដ្ឋប្បវេណី

១/. បង្គាប់ឱ្យឈ្មោះ [redacted] ប៊ុនធឿន សងសំណងរដ្ឋប្បវេណីទៅឈ្មោះ [redacted] ធី និងឈ្មោះ [redacted] សំបូរ ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារ, ឈ្មោះ [redacted] ស៊ីផូ ចំនួន ៩.០០០ (ប្រាំបួនពាន់) ដុល្លារ, និងឈ្មោះ [redacted] ជិននិមល ១.៥០០ (មួយពាន់ប្រាំរយ) ដុល្លារ នៅពេលសាលក្រមចូលជាស្ថាពរ។

២/. ក្នុងករណីបើឈ្មោះ [redacted] ប៊ុនធឿន មិនសងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ត្រូវអនុវត្តទោសដាក់ពន្ធនាគារបន្ថែមទៀត តាមមាត្រា៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

គ. ភស្តុតាង

ភស្តុតាងរួមមានដូចខាងក្រោម:

១/. រូបថតកាត់ត ចំនួន ១២ (ដប់ពីរ) សន្លឹក, វិញ្ញាបនបត្របញ្ជាក់ការសិក្សា (ក្លែងបន្លំ) ចំនួន ០២ (ពីរ) សន្លឹក, ប័ណ្ណសរសើរ (ក្លែងបន្លំ) ចំនួន ០១ (មួយ) សន្លឹក, ប្រកាសនីយបត្រគ្រឿងឥស្សរិយយសជាតូបការ (ក្លែងបន្លំ) ចំនួន ០១ (មួយ) សន្លឹក, ប្រកាសស្តីពីការដំឡើងឋានន្តរស័ក្តិនាយទាហាន (ក្លែងបន្លំ) ចំនួន ០១ (មួយ) សន្លឹក, រូបថតកាតចំនួន ៣៩ (សាមសិបប្រាំបួន) សន្លឹក និងអត្តសញ្ញាណប័ណ្ណនាយទាហាន (ក្លែងបន្លំ) ចំនួន ០១ (មួយ) សន្លឹក ត្រូវរឹបអូសទុកក្នុងសំណុំរឿង។

២/. អាវការងារដៃវែង ចំនួន ០៣ (បី), អាវសាហារីយែន ចំនួន ០៣ (បី), មួកឧត្តមសេនីយ៍ ចំនួន ០១ (មួយ), ស្បែកជើងកវែងពណ៌ខ្មៅ ចំនួន ០១ (មួយ) គូ, ស័ក្តិស្មា ចំនួន ០៣ (បី) គូ, ផ្លាកឈ្មោះ ចំនួន ០១ (មួយ), ផ្លាកសញ្ញាឋានុមាន ចំនួន ០១ (មួយ), ផ្លាកសញ្ញាក្រសួងការពារជាតិ ចំនួន ០១ (មួយ), ផ្លាកសញ្ញាឧត្តមសេនីយ៍ ចំនួន ០៣ (បី), និងមេដាយការងារ ចំនួន ០៤ (បួន) ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

៣/. អាវុធខ្លីម៉ាក CF98-9 លេខ 005046 07 236 ចំនួន ០១ (មួយ) ដើម, បង់គ្រាប់ពណ៌ខ្មៅ ចំនួន ០២ (ពីរ) បង់, គ្រាប់ចំនួន ២៥ (ម្ភៃប្រាំ) គ្រាប់, និងស្រោមអាវុធខ្លីស្បែកពណ៌ខ្មៅ ចំនួន ០១ (មួយ) ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ។

៤/. ទូរស័ព្ទដៃម៉ាកអុបប៉ូ (OPPO) ចំនួន ០២ (ពីរ) គ្រឿង, ស្រោមទូរស័ព្ទដៃចំនួន ០២ (ពីរ), និងស៊ីមកាតចំនួន ០៣ (បី) ត្រូវប្រគល់ឱ្យយកទៅប្រើប្រាស់វិញ នៅពេលសាលក្រមចូលជាស្ថាពរ។

ឃ. សាលក្រម

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវី ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ធី និងឈ្មោះ [redacted]ស៊ីផូ ចាត់ទុកជាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះឈ្មោះ [redacted]សំបូរ និងឈ្មោះ [redacted]ជិននិមល និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយអនុវត្តសាលក្រមនេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
ថ្ងៃសុក្រ ១០ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ ១០ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២
**ក្រឡាបញ្ជី**

[redacted]